ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិសន្តិសុខសង្គម
លេខ :......៨៧/២០..........ប.ស.ស.

# សេចក្ដីសម្រេច
# ស្ដីពី
# បែបបទ និងនីតិវិធីនៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស.

## ក្រុមប្រឹក្សាភិបាល នៃបេឡាជាតិសន្តិសុខសង្គម

- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្ដីពីការបង្កើតបេឡាជាតិសន្តិសុខសង្គម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៧១៣ អនក្រ.តត ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០ ស្ដីពីការតែងតាំងក្រុមប្រឹក្សាភិបាល នៃបេឡាជាតិសន្តិសុខសង្គម អាណត្តិទី១
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាភិបាល លើកទី១ អាណត្តិទី១ នាថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០

## សម្រេច

**ប្រការ ១.-**

ចេញវិធានសម្រាប់ការប្រជុំក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម ដើម្បីធានាដំណើរការ និងការប្រព្រឹត្តទៅរបស់អង្គប្រជុំប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។



អាសយដ្ឋានអគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ : ០២៣ ២៦ ០០ ០១ , ០២៣ ៨៨ ១០ ១៥
០២៣ ៩៩ ៥២ ១៩ , ០២៣ ៨៨ ១០ ១៦
ទូរសារ : ០២៣ ៨៨ ២៦ ២៣ , ប្រអប់សំបុត្រ P.O.Box 70
Website : www.nssf.gov.kh

**ប្រការ ២ _.**

ការប្រជុំក្រុមប្រឹក្សាភិបាល នៃបេឡាជាតិសន្តិសុខសង្គម ត្រូវដំណើរការតាមគោលការណ៍ដូចខាងក្រោម៖

**១. របបប្រជុំ**

- ក្រុមប្រឹក្សាភិបាលនៃប.ស.ស. មានរបបប្រជុំសាមញ្ញប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ព្រមទាំងប្រជុំវិសាមញ្ញតាមគំនិតផ្តួចផ្តើមរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬតាមការស្នើសុំពីសមាជិកក្រុមប្រឹក្សាភិបាល ឬពីអគ្គនាយក ប.ស.ស. តាមការចាំបាច់។
- ការប្រជុំសាមញ្ញប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ត្រូវធ្វើឡើងជាចាំបាច់ដោយមិនត្រូវឆ្លងខែបន្ទាប់នៃដំណាច់ត្រីមាស ឆមាស និងឆ្នាំ។ ការខកខានមិនបានប្រជុំក្រុមប្រឹក្សាភិបាល ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំគឺជាការទទួលខុសត្រូវផ្ទាល់របស់ប្រធានក្រុមប្រឹក្សាភិបាល។

**២. របៀបវារៈ**

- ការប្រជុំក្រុមប្រឹក្សាភិបាលធ្វើការពិភាក្សាលើរបៀបវារៈដែលបានគ្រោង។ របៀបវារៈត្រូវបានជូនដំណឹងមុនយ៉ាងតិច ១០(ដប់)ថ្ងៃ នៃថ្ងៃធ្វើការងារដល់គ្រប់សមាជិកក្រុមប្រឹក្សាភិបាល និងសមាជិកពាក់ព័ន្ធដទៃផ្សេងទៀត។

**៣. កូរ៉ុម**

- ការប្រជុំរបស់ក្រុមប្រឹក្សាភិបាល អាចប្រព្រឹត្តទៅបានលុះត្រាតែមានការចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាលលើសពី៥០(ហាសិប)ភាគរយ។ សមាជិករបស់ក្រុមប្រឹក្សាភិបាលអវត្តមានពុំអាចឱ្យគេជំនួសបានឡើយ។
- ប្រសិនបើកូរ៉ុមមិនគ្រប់គ្រាន់នោះ ប្រធានប្រឹក្សាភិបាលអាចកោះអញ្ជើញប្រជុំជាថ្មីក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃក្រោយ។ ការប្រជុំលើកក្រោយនេះមិនចាំបាច់តម្រូវឱ្យមានគ្រប់កូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈដែលខកខានពុំបានប្រជុំតាមការអញ្ជើញលើកទី១ ប៉ុណ្ណោះ។

**៤.វត្តមានសមាជិក**

- សមាជិកដែលចូលរួមប្រជុំត្រូវចុះហត្ថលេខាលើបញ្ជីវត្តមាន។

**៥. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃប.ស.ស.**

- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវអនុម័តតាមមតិភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានក្រុមប្រឹក្សាភិបាលមានឧត្តមានុភាព។
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដោយមានចុះហត្ថលេខារបស់ប្រធាននិងរក្សាទុកនៅទីស្នាក់ការរបស់ ប.ស.ស.។

**៦. កំណត់ហេតុនៃការប្រជុំក្រុមប្រឹក្សាភិបាល នៃប.ស.ស.**

- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាក្នុងកំណត់ហេតុ។កំណត់ហេតុត្រូវឆ្លុះបញ្ចាំងពីភាពពិតនៃការពិភាក្សារបស់អង្គប្រជុំ។ លេខាធិការនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវរៀបចំ និងផ្ញើសេចក្តីព្រាង

កំណត់ហេតុជូនសមាជិកក្រុមប្រឹក្សាភិបាលក្នុងរយៈពេល២(ពីរ)ថ្ងៃ ក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំនីមួយៗ។

- សមាជិកក្រុមប្រឹក្សាភិបាលមានរយៈពេល៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការងារគិតចាប់ពីកាលបរិច្ឆេទទទួលបានកំណត់ហេតុប្រជុំដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវ ឬ ផ្តល់មតិកែសម្រួលកំណត់ហេតុ។ ប្រសិនបើហួសកាលបរិច្ឆេទកំណត់រយៈពេល៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ ហើយមិនមានការឆ្លើយតបមកលេខាធិការដ្ឋានទេ ត្រូវចាត់ទុកថាឯកភាពលើរបាយការណ៍។
- ក្នុងរយៈពេល១០(ដប់)ថ្ងៃគិតចាប់ពីកាលបរិច្ឆេទនៃកិច្ចប្រជុំ ប្រធានក្រុមប្រឹក្សាភិបាលត្រូវចុះហត្ថលេខាលើកំណត់ហេតុដែលទទួលបានការកែតម្រូវ ឬ ការយល់ព្រមពីសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់។
- កំណត់ហេតុអង្គប្រជុំក្រុមប្រឹក្សាភិបាល និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលខាងលើ ត្រូវបញ្ជូនក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងជូនសមាជិកអង្គប្រជុំ។

**៧. មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ នៃប.ស.ស.**

- មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវចូលរួមក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាលតែមិនមានសិទ្ធិបោះឆ្នោត។

**ប្រការ ៣ .-**

សេចក្តីសម្រេចនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៣រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០

**ជ. ក្រុមប្រឹក្សាភិបាល នៃប.ស.ស.**

**ប្រធាន**

**អ៊ិត សំហេង**

**ចម្លងជូន:**

- ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- សមាជិកក្រុមប្រឹក្សាភិបាលនៃប.ស.ស.

  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ